# របាយការណ៍ប្រចាំខែឧសភា ឆ្នាំ ២០១៦ របស់មន្ទីរអភិវឌ្ឍន៍ជនបទ ខេត្តឧត្តរមានជ័យ

**១. សេចក្តីផ្តើម**

ខេត្តឧត្តរមានជ័យស្ថិតនៅទិសឧត្តរនៃព្រះរាជាណាចក្រកម្ពុជា មានចម្ងាយប្រមាណជា ៤៤៧ គីឡូម៉ែត្រ ពីរាជធានីភ្នំពេញ មានផ្ទៃដីសរុបចំនួន ៦.៦៣១,៧២ គីឡូម៉ែត្រក្រឡា។ ខេត្តនេះមានព្រំប្រទល់ខាងកើតជាប់នឹងខេត្តព្រះវិហារ ខាងលិចជាប់នឹងខេត្តបន្ទាយមានជ័យ ខាងត្បូងជាប់នឹងខេត្តសៀមរាប និងខាងជើងប្រវែង ២២៥ គីឡូម៉ែត្រជាប់នឹងខេត្តស៊ីសាកេត ខេត្តបុរីរ៉ុំ និងខេត្តសុរិន្ទ្រ ប្រទេសថៃ និងមានស្រុកចំនួន ០៤ និងក្រុង ១ គឺស្រុកអន្លង់វែង ស្រុកត្រពាំងប្រាសាទ ស្រុកចុងកាល់ ស្រុកបន្ទាយអំពិល និងក្រុងសំរោង។

**២. ស្ថានភាពរបស់មន្ទីរ**

**២.១ ការងាររដ្ឋបាល និងបុគ្គលិក**

មន្ទីរអភិវឌ្ឍន៍ជនបទខេត្តឧត្តរមានជ័យ ដឹកនាំដោយប្រធានមន្ទីរ ០១ រូប និងអមដោយអនុប្រធានមន្ទីរចំនួន ០២ រូប រួមមាន បុគ្គលិកសរុបចំនួន ៣៣ នាក់ ក្នុងនោះនៅកម្រិតរដ្ឋបាលថ្នាក់មន្ទីរមានការិយាល័យជំនាញចំនួន ០៨ និងថ្នាក់ស្រុក ០៥។

**២.២ កិច្ចប្រជុំផ្សេងៗ និងទំនាក់ទំនងសាធារណៈ:**

- ថ្ងៃទី ០២-០៥ ខែឧសភា លោកប្រធានមន្ទីរ និងមន្ត្រីការិយាល័យគណនេយ្យ ០៣ រូប ចូលរួមសិក្ខាសាលា ស្តីពីនីតិវិធីអនុវត្តការងាររដ្ឋទេយ្យថវិកាកម្មវិធីសម្រាប់អង្គភាពថវិកា ក្រោមអធិបតីភាព ឯកឧត្តម **ឃឹម ប៊ុនសុង** អភិបាលនៃគណៈអភិបាល ខេត្តសៀមរាប នៅសណ្ឋាគារ អ៊ីមជ្រេសអង្គរ ខេត្តសៀមរាប
- ថ្ងៃទី ០៥ ខែឧសភា ថ្នាក់ដឹកនាំមន្ទីរ ចូលរួមពិធីអនុស្សាវរីយ៍លើកទី ១៣០ នៃទិវាពលកម្មអន្តរជាតិថ្ងៃទី ០១ ខែឧសភា ឆ្នាំ ២០១៦ ក្រោមអធិបតីភាព ឯកឧត្តម **ស ថាវី** អភិបាលនៃគណៈអភិបាល ខេត្តឧត្តរមានជ័យ នៅមន្ទីរទំនាក់ទំនងជាមួយរដ្ឋសភា ព្រឹទ្ធសភា និងអធិការកិច្ចខេត្ត
- ថ្ងៃទី ១០ ខែឧសភា ថ្នាក់ដឹកនាំមន្ទីរ ចូលរួមប្រជុំ Pro TWG-H ប្រចាំខែមេសា ឆ្នាំ ២០១៦ នៅមន្ទីរសុខាភិបាលខេត្ត
- ថ្ងៃទី ១០ ខែឧសភា លោកប្រធានមន្ទីរ ចូលរួមប្រជុំសាមញ្ញលើកទី ២៨ របស់ក្រុមប្រឹក្សាខេត្ត ឆ្នាំទី ២ អាណត្តិទី ២ នៅសាលប្រជុំសាលាខេត្តឧត្តរមានជ័យ និង
- ថ្ងៃទី ១២ ខែឧសភា លោកប្រធានមន្ទីរ ចូលរួមចុះដោះស្រាយផលប៉ះពាល់គម្រោងស្ថាបនាអាងស្តុកទឹក និងផ្លូវ ស្ថិតនៅចំណុចអូរថ្ម ឃុំត្រពាំងប្រិយ៍ ស្រុកអន្លង់វែង ក្រោមអធិបតីភាព ឯកឧត្តម **ស ថាវី** អភិបាលនៃគណៈអភិបាលខេត្តឧត្តរមានជ័យ។

## ៣. លទ្ធផលសម្រេចបានតាមវិស័យ

### ៣.១ ការងារផ្លូវជនបទ

- ចុះត្រួតពិនិត្យតាមដានបទដ្ឋានបច្ចេកទេសខ្សែផ្លូវកំពុងសាងសង់នៅភូមិបាត់ថ្កៅ ឃុំចុងកាល់ ស្រុកចុងកាល់ ប្រវែងសរុប ៤.៥០០ ម៉ែត្រ
- ចុះត្រួតពិនិត្យតាមដានបទដ្ឋានបច្ចេកទេសខ្សែផ្លូវជួសជុលខួប កំពុងសាងសង់ចាប់ពីភូមិគោកផ្ទង់ ដល់ភូមិគោកត្រាង ឃុំជើងទៀន ស្រុកចុងកាល់ប្រវែងសរុប ៨.០០០ ម៉ែត្រ និង
- លោកប្រធានមន្ទីរ បានដឹកនាំក្រុមការងាររបស់នាយកដ្ឋានផ្លូវជនបទ របស់ក្រសួងអភិវឌ្ឍន៍ជនបទ និងក្រុមការងាររបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ចុះត្រួតពិនិត្យ និងសិក្សាពីគម្រោងផ្លូវជួសជុលបន្ទាន់ ស្ថិតក្នុងភូមិបន្ទាយថ្មី ឃុំចុងកាល់ ស្រុកចុងកាល់ ប្រវែងសរុប ១.៣០០ ម៉ែត្រ។

### ៣.២ ការងារផ្គត់ផ្គង់ទឹកស្អាត

- បានសាងសង់អណ្តូងស្នប់ ០៨ អណ្តូង រួមមាន÷
    - នៅភូមិគីរីបង្គល សង្កាត់សំរោង ០៣អណ្តូង មានទឹក ០១អណ្តូង និងគ្មានទឹក ០២ អណ្តូង
    - ភូមិឈើក្រំ សង្កាត់កូនក្រៀល ក្រុងសំរោង បានខួង និងតម្លើងបំពង់រួចចំនួន ០២ អណ្តូង
    - ភូមិកុល សង្កាត់កូនក្រៀល ក្រុងសំរោង បានខួង និងតម្លើងបំពង់រួចចំនួន ០២ អណ្តូង និង
    - ភូមិបុរីរដ្ឋបាលសង្កាត់ក្រុងសំរោង ក្រុងសំរោង បានខួង និងតម្លើងបំពង់រួចចំនួន ០១ អណ្តូង ។
- បានជួសជុលអណ្តូងស្នប់ ០៣ អណ្តូង រួមមាន÷
    - ភូមិប្រាសាទ ០១ អណ្តូង សង្កាត់បុស្សរ ក្រុងសំរោង បានជួសជុលរួច
    - ភូមិអូរស្មាច់ ០១ អណ្តូង សង្កាត់អូរស្មាច់ ក្រុងសំរោង បានជួសជុលរួច
    - ភូមិចំការចេក ០១ អណ្តូង សង្កាត់អូរស្មាច់ ក្រុងសំរោង បានជួសជុលរួច
- ចុះជ្រើសរើសទីតាំងបាន ០៤ អណ្តូង រួមមាន÷ បានចុះត្រួតពិនិត្យ និងវាយតម្លៃអណ្តូងស្នប់ខូចសម្រាប់ជួសជុល និងស្តារឡើងវិញចំនួន ០៤ អណ្តូងមានទីតាំងនៅភូមិ “ក” ០៣ អណ្តូង និងភូមិគោកវត្ត ០១ អណ្តូង ឃុំចុងកាល់ ស្រុកចុងកាល់។

### ៣.៣ ការងារអភិវឌ្ឍន៍សហគមន៍

មន្ត្រីការិយាល័យ ០៣ រូប សហការជាមួយអង្គការ FH Cambodia បានចុះបើកវគ្គបណ្តុះបណ្តាលស្តីពីការអភិវឌ្ឍន៍សមត្ថភាពរបស់គណៈកម្មាធិការអភិវឌ្ឍន៍ភូមិ (គ.អ.ភ) ចំនួន០២វគ្គ ។ អ្នកចូលរួមសរុប ៨០ នាក់ នៅស្រុកត្រពាំងប្រាសាទ។

### ៣.៤ ការអភិវឌ្ឍន៍ព្រំដែនទិសខាងជើង និងខាងលិចប្រទេស

**ការងារសាងសង់ផ្ទះ÷** ភូមិតាមាន់សែនជ័យបានធ្វើការសាងសង់ផ្ទះរួចរាល់ជាស្ថាពរចំនួន **៣៨ ខ្នង**

ក្នុងជំហានទី ៤ នៅភូមិតាមាន់សែនជ័យ ស្រុកបន្ទាយអំពិល ខេត្តឧត្តរមានជ័យ។

**៤. ទិសដៅការងារបន្ត**

- ចុះត្រួតពិនិត្យតាមដានបទដ្ឋានបច្ចេកទេសខ្សែផ្លូវជួសជុលដែលកំពុងអនុវត្ត
- ចុះត្រួតពិនិត្យ និងសិក្សាខ្សែផ្លូវជួសជុលបន្ទាន់ និងសាងសង់ថ្មីទូទាំងខេត្ត សម្រាប់ការអនុវត្តក្នុងឆ្នាំ ២០១៦
- ចុះប្រមូលទិន្នន័យខ្សែផ្លូវថ្មី និងធ្វើបច្ចុប្បន្នភាពសម្រាប់ ឆ្នាំ ២០១៦
- សាងសង់អណ្តូងស្នប់អាហ្វ្រិដេវចំនួន ១១ អណ្តូង
- សាងសង់ធុងចម្រោះទឹកស្អាតចំនួន ១០០ ធុង និង
- បន្តសហការជាមួយអង្គការ FH Cambodia ដើម្បីចុះបើកវគ្គបណ្តុះបណ្តាល គ.អ.ភ នៅភូមិគោលដៅ។